**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**

លេខ......១៩៤៤......អ.ន.ក

# សេចក្តីជូនដំណឹង

អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ជាម្ចាស់រោងចក្រកែច្នៃ និងវេចខ្ចប់ម្រេច និងចម្ការម្រេច ជ្រាបថា ពិធីសារស្តីពីលក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់ការនាំចេញម្រេចពីប្រទេសកម្ពុជាទៅកាន់ប្រទេសចិន ត្រូវបានចុះហត្ថលេខាដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមួយអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២២ កន្លងទៅថ្មីៗនេះ។

អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់ម្ចាស់ចម្ការម្រេច សហគមន៍កសិកម្មម្រេច និងម្ចាស់រោងចក្រកែច្នៃនិងវេចខ្ចប់ម្រេច ដែលមានបំណងផលិតនិងកែច្នៃវេចខ្ចប់នាំចេញម្រេចទៅកាន់ទីផ្សារប្រទេសចិន រួសរាន់ដាក់ពាក្យស្នើសុំចុះបញ្ជីចម្ការ និងម្ចាស់រោងចក្រកែច្នៃនិងវេចខ្ចប់ម្រេចសម្រាប់នាំចេញទៅកាន់ប្រទេសចិននៅអគ្គនាយកដ្ឋានកសិកម្ម។

បន្ទាប់ពីទទួលបាននូវពាក្យស្នើសុំ អគ្គនាយកដ្ឋានកសិកម្មនឹងចាត់មន្ត្រីជំនាញចុះវាយតម្លៃស្របតាមនីតិវិធីបច្ចេកទេសដូចមានចែងក្នុងពិធីសារ។ អគ្គនាយកដ្ឋានកសិកម្មគ្រោងនឹងបញ្ជូនបញ្ជីឈ្មោះចម្ការ និងរោងចក្រកែច្នៃនិងវេចខ្ចប់ម្រេចទៅកាន់ភាគីចិននៅដើមខែមករា ឆ្នាំ២០២៣ ខាងមុខ ដើម្បីភាគីចិនពិនិត្យនិងវាយតម្លៃបញ្ជាប់មុននឹងឈានដល់ការនាំចេញជាផ្លូវការ។

សម្រាប់ព័ត៌មានបន្ថែម សូមធ្វើការទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០១២ ៣២៥ ៥៥៨, ០១២ ៥៣៣ ៦៤៧, ០១២ ២២៤ ៨១៥ និង ០៧៧ ៤២៦ ៦០៨។

ថ្ងៃ ច័ន្ទ ៤រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័កព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០២២
**អគ្គនាយកដ្ឋានកសិកម្ម**

អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ: (០២៣) ៨៨៣ ៤២៧. ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ......................

## ពាក្យស្នើសុំចុះបញ្ជីចម្ការម្រេច និងរោងចក្រវេចខ្ចប់សម្រាប់នាំចេញផ្លែម្រេចទៅកាន់ប្រទេសចិន

ខ្ញុំបាទ □ / នាងខ្ញុំ □ ឈ្មោះ : ..........................................................................................................

កាន់អត្តសញ្ញាណប័ណ្ណ / លិខិតឆ្លងដែនលេខ : .................................................. ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ..........

ជាប្រធានក្រុមហ៊ុន : ..........................................................................................................

ឬជាម្ចាស់ចម្ការ : ..........................................................................................................

អាសយដ្ឋានក្រុមហ៊ុន : ..........................................................................................................

ទូរស័ព្ទទំនាក់ទំនង : ..........................................................................................................

**<u>សូមគោរពជូន</u>**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម**

**<u>កម្មវត្ថុ:</u>** សំណើសុំការត្រួតពិនិត្យវាយតម្លៃដើម្បីទទួលបានការចុះបញ្ជីចម្ការម្រេច □ និងរោងចក្រវេចខ្ចប់ □ សម្រាប់នាំចេញផ្លែម្រេចទៅកាន់ប្រទេសចិន។

**<u>ឯកសារជូនភ្ជាប់៖</u>**

| | | |
|---|---|---|
| ១. លិខិតអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្ម ដែលកំណត់ពីកម្មវត្ថុអាជីវកម្ម | □ | លេខ.......... ចុះថ្ងៃទី......../........../......... |
| ២. វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម | □ | លេខ.......... ចុះថ្ងៃទី......../........./........... |
| លេខអត្តសញ្ញាណកម្មសារពើពន្ធ (VAT) | □ | លេខ.......... ចុះថ្ងៃទី......../........./........... |
| ៣. ប័ណ្ណប៉ាតង់ឆ្នាំចុងក្រោយ (ស្ថិតក្នុងសុពលភាព) | □ | លេខ.......... ចុះថ្ងៃទី......../........./........... |
| ៤. ប្លង់កម្មសិទ្ធកាន់កាប់ដីចម្ការ | □ | លេខ.......... ចុះថ្ងៃទី......../........./........... |
| ៥. ឯកសារបច្ចេកទេសរបស់ក្រុមហ៊ុនស្តីពីការគ្រប់គ្រងចម្ការម្រេច | | |
| ៦. លិខិតផ្លូវការដទៃដែលពាក់ព័ន្ធ (ប្រសិនបើមាន)៖ | □ | ..........................................................<br>.......................................................... |

(បណ្តាឯកសារពាក់ព័ន្ធដទៃទៀត ដែលមានប្រសិទ្ធភាពគាំទ្រការវាយតម្លៃ និងប្រគល់ជូនបន្ថែមតាមការចាំបាច់)

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពអនុញ្ញាតជម្រាបជូន **ឯកឧត្តមប្រតិភូ** មេត្តាជ្រាបថា ក្នុងគោលបំណងចូលរួមចំណែកជំរុញការនាំចេញផលិតផលកសិកម្មកម្ពុជាទៅកាន់ទីផ្សារប្រទេសចិន ក្រុមហ៊ុនយើងខ្ញុំបានធ្វើការដាំដុះដំណាំម្រេច □ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ □ សម្រាប់គាំទ្រការនាំចេញផ្លែម្រេចទៅកាន់ប្រទេសចិន។

ដើម្បីត្រៀមលក្ខណៈការចុះត្រួតពិនិត្យ វាយតម្លៃពីអគ្គរដ្ឋបាលគយចិន ក្រុមហ៊ុនយើងខ្ញុំគោរពស្នើសុំមន្ត្រីជំនាញពីនាយកដ្ឋានការពាររុក្ខជាតិ អនាម័យ និងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម ចុះត្រួតពិនិត្យ និងផ្តល់ដំបូន្មានសម្រាប់ធ្វើការលម្អ (ក្នុងករណីមិនទាន់សមស្របតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យ) ឱ្យបានមុនការមកដល់របស់មន្ត្រីនៃអគ្គរដ្ឋបាលគយចិន។

សូម**ឯកឧត្តមប្រតិភូ**មេត្តាពិនិត្យ និងសម្រេចធ្វើការពិនិត្យវាយតម្លៃក្រុមហ៊ុនយើងខ្ញុំ ដើម្បីទទួលបានការចុះបញ្ជីចម្ការម្រេច □ និងរោងចក្រវេចខ្ចប់ □ ដើម្បីនាំចេញផ្លែម្រេចទៅកាន់ប្រទេសចិន ដោយអនុគ្រោះ។

ក្រុមហ៊ុនយើងខ្ញុំ នឹងទទួលការសហការ និងគាំទ្រសកម្មភាពចុះត្រួតពិនិត្យវាយតម្លៃរបស់អគ្គនាយកដ្ឋានកសិកម្ម។

រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.............. ឆ្នាំ.................

ហត្ថលេខា និងត្រាក្រុមហ៊ុន